UNITED STATES DISTRICT COURT
EASTERN DISTRICT OF LOUISIANA
តុលាការដំបូងរបស់សហរដ្ឋអាមេរិក
សង្កាត LOUISIANA ខាងកើត

| | | |
|---|---|---|
| ទាក់ទងនឹង៖ ការធ្លាយប្រេង ដោយសារការខួងយកប្រេង "តំបន់ទឹកជ្រៅ (Deepwater Horizon)" នៃតំបន់ឆ្នេរជាប់ឈូងសមុទ្រ Mexico ថ្ងៃទី20 ខែមេសា ឆ្នាំ 2010 | * * * * | MDL No. 2179 ជំពូក: J |
| | * | ចៅក្រម BARBIER |
| | * | ព្រះរាជអាជ្ញា SHUSHAN |
| ឯកសារនេះអនុវត្តចំពោះ៖ រាល់រឿងក្តីទាំងអស់ (រួមទាំង 10-2771) | * * | |

## <u>ដីការ</u>

**[ធ្វើវិសោធនកម្ម និងលុបចោលដីការកាលពីលើកមុនរបស់តុលាការដែលចុះថ្ងៃទី 28 ខែធ្នូ ឆ្នាំ2011(ឯកសារលេខ 5022) និងដីការចុះថ្ងៃទី 4 ខែមករា ឆ្នាំ2012 (ឯកសារលេខ 5064) ក្នុងការបង្កើតគណនី និងការតម្កល់ប្រាក់សំណង]**

នៅចំពោះមុខតុលាការ គឺពាក្យបណ្តឹងរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ស្នើសុំការបំភ្លឺ និងការពិចារណាឡើងវិញលើដីការ និងមូលហេតុរបស់តុលាការចុះថ្ងៃទី 28 ខែធ្នូ ឆ្នាំ2011 (ឯកសារលេខ 5044)[1]។ ក្រុមហ៊ុនប្រេងប៊ីភី BP បានស្នើឲ្យពិចារណាលើពាក្យបណ្តឹងរបស់ខ្លួនឲ្យបានឆាប់ ដែលតុលាការទទួលយក (ឯកសារលេខ 5083) ដែលបង្គាប់ថា បណ្តឹងឆ្លើយតបចំពោះពាក្យបណ្តឹងរបស់ក្រុមហ៊ុនប្រេងប៊ីភី BP ត្រូវបានដាក់នៅមុនថ្ងៃទី 12 ខែមករា ឆ្នាំ2012។ តុលាការបានទទួល និងពិចារណាលើបណ្តឹងឆ្លើយតបពីភាគីជាច្រើន ក្នុងនោះមាន គណៈកម្មការរបស់ដើមចោទ ("PSC") សហរដ្ឋអាមេរិក អគ្គមេធាវីនៃរដ្ឋ Alabama និងពីបុគ្គលមិនមែនជាភាគីជាច្រើននាក់ ក្នុងនោះមាន អគ្គមេធាវីនៃរដ្ឋMississippi និងរដ្ឋ Florida ក៏ដូចជាមេធាវីជាច្រើននាក់ដែលមិនមែនជា PSC។

---

[1] ដីការរបស់តុលាការចុះថ្ងៃទី 28 ខែធ្នូ ឆ្នាំ 2011 ត្រូវបានធ្វើវិសោធនកម្មដោយសេចក្តីសម្រេចចុះថ្ងៃទី 4 ខែមករា ឆ្នាំ 2012 (ឯកសារលេខ 5064) ដើម្បីបំភ្លឺថា ដីការតម្កល់ប្រាក់សំណងនឹងអនុវត្តនៅថ្ងៃអនាគតតែប៉ុណ្ណោះ។

នៅចំពោះមុខតុលាការនេះផងដែរ គឺពាក្យបណ្តឹងរួមស្នើសុំដីកាដែលជាសំណើ និងបានព្រមព្រៀងគ្នា ដែលបានដាក់ដោយអគ្គមេធាវីនៃរដ្ឋ Louisiana និងរដ្ឋ Alabama និង PSC។ (ឯកសារលេខ 5230)។

បន្ទាប់ពីបានពិចារណាលើពាក្យបណ្តឹងទាំងនេះ និងបណ្តឹងឆ្លើយតបផ្សេងៗ តុលាការ**ទទួលយក**ពាក្យសុំបំភ្លឺ និងពិចារណាឡើងវិញរបស់ក្រុមហ៊ុនប្រេងប៊ីភី BP (ឯកសារលេខ 5044) និង**ទទួលយក**ពាក្យបណ្តឹងរួមស្នើសុំសេចក្តីសម្រេចដែលជាសំណើ និងបានព្រមព្រៀង ដោយអគ្គមេធាវីនៃរដ្ឋ Louisiana និងរដ្ឋ Alabama (ឯកសារលេខ 5230) ហើយ**ធ្វើវិសោធនកម្ម** និង**លុបចោល**ដីការកាលពីលើកមុនរបស់តុលាការ (ឯកសារលេខ 5022 និង 5064) ដូចតទៅ៖

**ដីការបានចែង**ថា ចុងចោទត្រូវបង់និងត្រូវបានដកយក (4%) ស្មើនឹងបួនភាគរយនៃបរិមាណទឹកប្រាក់ចំពោះការដោះស្រាយរឿងក្តីទាំងស្រុង មូលនិធិសាលក្រម ឬមូលនិធិផ្សេងទៀតដែលបង់ដោយឬក្នុងនាមចុងចម្លើយម្នាក់ឬច្រើន ទៅរដ្ឋ Alabama ឬរដ្ឋ Louisiana ឬស្ថាប័នរដ្ឋាភិបាលរបស់ពួកគេ ដែលបណ្តាលមកពីគ្រោះមហន្តរាយ Macondo/Deepwater Horizon[2] នៅក្នុងគណនីសម្រាប់ទូទាត់សំណងដែលគ្រប់គ្រងដោយតុលាការ ក្នុងគោលបំណងបង្កើតមូលនិធិដែលអាចយកទៅបង់ប្រាក់ប្រដាប់ក្តី និងការចំណាយលើផលប្រយោជន៍រួម ប្រសិនបើ និងដូចដែលបានសម្រេចដោយតុលាការ នៅពេលសមស្រប អនុលោមតាមនីតិវិធីដែលបានកំណត់ ដែលនឹងសម្រេចដោយដីការតុលាការនៅថ្ងៃអនាគត។

ការដកយកប្រាក់ 4% ដែលអនុវត្តចំពោះដំណោះស្រាយ សាលក្រម ឬមូលនិធិផ្សេងទៀតដែលត្រូវបង់ទៅឲ្យរដ្ឋ Louisiana និងរដ្ឋ Alabama មិនត្រូវអនុវត្តចំពោះ (1) ចំនួនប្រាក់ណាមួយដែលរដ្ឋទទួលបានមកវិញ ទោះប្រភេទណាក៏ដោយ ដែលបានបង់ពីមុន មុនពេលកាលបរិច្ឆេទចេញសេចក្តីសម្រេចនេះ ឬត្រូវបង់បន្ទាប់ពីចេញសេចក្តីសម្រេចនេះ អនុលោមតាមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាកន្លងមករវាងរដ្ឋ Louisiana និង/ឬ រដ្ឋ Alabama (ជាភាគីតែមួយ ឬមួយនៃពហុភាគី) និងចុងចម្លើយមុនកាលបរិច្ឆេទចេញដីការនេះ និង (2) ចំនួនប្រាក់ណាមួយដែលរដ្ឋទទួលបានមកវិញ (ឬអត្ថប្រយោជន៍) ចំពោះកម្រៃបណ្តឹងឆ្លើយតប កម្រៃទីភ្នាក់ងារដែលកើនឡើងទាក់ទងនឹងបណ្តឹងឆ្លើយតប ការខូចខាតធន

---

2 លក្ខខណ្ឌឲ្យបង់ "ចំនួនទឹកប្រាក់សមមូល" ជាភាគរយកំណត់ គឺដើម្បីផ្តល់ភាពបត់បែនដល់ភាគីនានាក្នុងការចរចាដោះស្រាយបណ្តឹង។ ជាការសន្មត់ ដើមចោទនឹងមានបំណងចរចាវិវាទជាមួយចុងចម្លើយមួយឬច្រើនដែលចុងចម្លើយអាចយល់ព្រមបង់ប្រាក់កម្រៃលើផលប្រយោជន៍រួម(និង/ឬកម្រៃសេវាមេធាវីផ្សេងៗ)ឲ្យលើសពីដំណោះស្រាយបណ្តឹង ដែលជាផ្នែកមួយនៃដោះស្រាយបណ្តឹងតាមរយៈការចរចា។ ប៉ុន្តែក្នុងករណីដែលចុងចម្លើយមិនចង់ដាក់ប្រាក់បម្រុងឲ្យលើសពីដំណោះស្រាយបណ្តឹង ប្រាក់បម្រុង(ក្នុងករណីគ្មានសាលក្រមស្ថាពរ ឬសាលក្រមផ្សេងទៀតដែលតម្រូវឲ្យចុងចម្លើយបង់កម្រៃមួយភាគឬទាំងអស់លើសេវាមេធាវី) គួរតែត្រូវបម្រុងទុកឬ "កាត់ពី" មូលនិធិសាលក្រម មូលនិធិដោះស្រាយបណ្តឹង ឬមូលនិធិផ្សេងៗទៅដើមចោទ រង់ចាំចំណាត់ការនាពេលអនាគតដោយតុលាការ។ ទោះបីដើមចោទអាចរក្សាសិទ្ធិក្នុងការស្វែងរកផលប្រយោជន៍និង/ឬកម្រៃសេវាមេធាវីផ្សេងទៀត តាមបទប្បញ្ញត្តិអំពីការចែករំលែកកម្រៃសេវា គ្មានអ្វីនៅក្នុងសាលក្រម*នេះ* អាច*តម្រូវឲ្យ* ចុងចម្លើយមួយបង់ប្រាក់កម្រៃ ដើម្បីផលប្រយោជន៍រួមរបស់ដើមចោទនិង/ឬកម្រៃសេវាមេធាវីឡើយ។

ធានធម្មជាតិ ("NRD") ការវាយតម្លៃ NRD ការចំណាយដទៃទៀតណាមួយដែលចំណាយតាមរយៈការចូលរួមក្នុងការវាយតម្លៃ NRD ប្រាក់ពិន័យរបស់រដ្ឋ ឬសហព័ន្ធ (ឧ. ប្រាក់ពិន័យតាមច្បាប់ទឹកស្អាត) (ដោយលើកលែងប្រាក់ពិន័យដែលស្នើសុំដោយមេធាវីសង្កាត់ តាម La. R.S. 56:40.1, et seq.) ប្រាក់សម្អាតកាកសំណល់ពីមូលនិធិសម្រាប់ការធ្លាយប្រេងរបស់រដ្ឋ ឬសហព័ន្ធ គម្រោងបរិស្ថានបន្ថែម និងរបស់មិនមែនជាប្រាក់ដទៃទៀតដែលទទួលបានមកវិញ។ ដំណោះស្រាយសាលក្រម ឬការទូទាត់ផ្សេងៗនៃរដ្ឋ Louisiana និង/ឬ រដ្ឋ Alabama ងាយនឹងត្រូវបានដកយកចំនួន 4%។

**ដីការបានចែងបន្ថែមទៀតថា** ចុងចម្លើយ ឬទីភ្នាក់ងារ ឬតំណាងឲ្យចុងចម្លើយ ត្រូវកាត់ទុក និងតម្កល់ប្រាក់ស្មើនឹងប្រាំមួយភាគរយ (6%) នៃបរិមាណទឹកប្រាក់នៃដំណោះស្រាយសរុប សាលក្រម និងមូលនិធិដទៃទៀតដែលត្រូវបង់នៅ ឬក្រោយថ្ងៃទី30 ខែធ្នូ ឆ្នាំ2011 ដោយ ឬក្នុងនាមចុងចម្លើយម្នាក់ ឬច្រើនទៅឲ្យដើមចោទ ឬអ្នកទាមទារសំណងមានកម្រិត ដែលបច្ចុប្បន្ន ឬក្រោយមក អាចមានបណ្តឹង ឬមានបណ្តឹងទាមទារសំណងមានកម្រិត ដែលរង់ចាំការសម្រេចក្នុងបណ្តឹងសមូហភាព (ដោយលើកលែងការដោះស្រាយបណ្តឹង ការចេញសាលក្រមឬការចំណាយផ្សេងៗទៅលើសហរដ្ឋអាមេរិក) ទៅក្នុងគណនីសម្រាប់ទូទាត់សំណងដែលគ្រប់គ្រងដោយតុលាការ ក្នុងគោលបំណងបង្កើតមូលនិធិដែលអាចយកទៅបង់ប្រាក់ឈ្នួលសម្រាប់រៀងក្តី និងការចំណាយលើផលប្រយោជន៍រួម ប្រសិនបើ និងដូចដែលបានសម្រេចដោយតុលាការ នៅពេលសមស្រប អនុលោមតាមនីតិវិធីដែលបានកំណត់ ដែលនឹងសម្រេចដោយតុលាការ[3] នៅថ្ងៃអនាគត។ ជាពិសេស លក្ខខណ្ឌកាត់ទុកនេះអនុវត្តចំពោះរាល់បណ្តឹងទាំងអស់ដែលបានដាក់ ឬប្តូរទៅតុលាការសហព័ន្ធ ដែលជាបណ្តឹងសមូហភាពទាំងស្រុង ឬមួយផ្នែក ទោះបីជាពាក្យបណ្តឹងឲ្យបញ្ជូនមកវិញត្រូវបានដាក់ឬយ៉ាងណាក៏ដោយ និងអនុវត្តចំពោះដើមចោទ ដែលជាតុលាការរដ្ឋតំណាងដោយមេធាវីដែលបានចូលរួម ឬមិនលទ្ធភាពពិនិត្យលទ្ធផលស្វែងរក ក្នុងបណ្តឹងសមូហភាព (MDL)។ លក្ខខណ្ឌនៃការដកយកនេះត្រូវលើកលែងចំពោះដំណោះស្រាយ ឬប្រាក់ដទៃទៀតដែលបង់ដោយស្ថាប័នសម្របសម្រួលពាក្យបណ្តឹងតំបន់ឆ្នេរជាប់ឈូងសមុទ្រ (GCCF) អ្នកពិនិត្យបណ្តឹង ឬចុងចម្លើយ ទៅឲ្យអ្នកទាមទារបណ្តឹងដែលមិនធ្លាប់មាន បច្ចុប្បន្នមិនមាន ឬក្រោយមកមិនមានបណ្តឹង ឬការទាមទារសំណងមានកម្រិត រង់

[3] ក្នុងករណីដែលចុងចម្លើយមិនយល់ព្រមបង់ប្រាក់តាមការកំណត់ភាគរយលើការដោះស្រាយបណ្តឹង, *សូមមើលកំណត់បង្ហាញ*លេខ 1, តុលាការមានបំណងថារាល់ដើមចោទដែលត្រូវបានតំណាងដោយក្រុមប្រឹក្សាការកាត់ប្រាក់ត្រូវដកប្រាក់ពីកម្រៃសេវាមេធាវី ជាជាងយកពីការជួសជុលចំណងសមាមាត្ររបស់ អតិថិជន។

ចាំការសម្រេចក្នុងបណ្តឹងសមូហភាពឡើយ។ លក្ខខណ្ឌដកយកនេះត្រូវលើកលែងផងដែរចំពោះមេធាវីការពារតុលាការរដ្ឋ ដែលមាន ឬគ្មានរឿងក្តីក្នុងបណ្តឹងសមូហភាព និងដែលមិនមានលទ្ធភាពពិនិត្យលទ្ធផលស្វែងរក ដែលធ្វើឡើងក្នុងបណ្តឹងសមូហភាព។

ម្យ៉ាងទៀត លក្ខខណ្ឌដកយកនេះមិនត្រូវអនុវត្តចំពោះសំណើដំណោះស្រាយដែលមានក្នុងលិខិតកំណត់ការទូទាត់សំណងពីស្ថាប័ន GCCF (ឬក្រុមហ៊ុនប្រេងប៊ីភី BP ទាក់ទងនឹងបណ្តឹងទាមទារសំណងការខូចខាតនាវាកៀប្រេង) ដែលចេញនៅ ឬមុនថ្ងៃទី 30 ខែធ្នូ ឆ្នាំ2011។ លើសពីនេះ នៅពេលក្រុមហ៊ុនប្រេងប៊ីភី BP ចុងចម្លើយដទៃទៀត ស្ថាប័ន GCCF ឬអ្នកពិនិត្យបណ្តឹងទាមទារដទៃទៀត ដកយកប្រាក់ (ឬចំណែកនៃប្រាក់) អនុលោមតាមសិទ្ធិឃាត់ទុកតាមច្បាប់ ឬដីការឹបអូស លក្ខខណ្ឌនេះត្រូវអនុវត្តតែចំពោះចំណែកប្រាក់នៃដំណោះស្រាយ ឬសំណងនោះ ដែលមិនត្រូវឃាត់ទុក ឬរឹបអូសឡើយ (ដូចជា "ចំនួនប្រាក់សុទ្ធ" ដែលសល់ពីការកាត់ប្រាក់ប្រដាប់ក្តី ឬទ្រព្យរឹបអូស)។

គ្មានប្រការណាមួយក្នុងដីការនេះមានគោលបំណងអនុវត្តលើសាលក្រម ដំណោះស្រាយ ឬមូលនិធិផ្សេងទៀតរវាង ឬក្នុងចំណោមក្រុមហ៊ុនប្រេងប៊ីភី BP Transocean Cameron Halliburton Weatherford M-I Anadarko MOEX និង/ឬចុងចម្លើយដទៃទៀត ឬអ្នកធានារ៉ាប់រងណាមួយរបស់ពួកគេឡើយ។

គ្មានកម្រៃ និង/ឬចំណាយលើអត្ថប្រយោជន៍រួមត្រូវផ្តល់ជូនក្រៅពីគណនីបម្រុង MDL 2179 ឡើយលើកលែងតែតាមរយៈបណ្តឹងផ្លូវការ ដែលបានជូនដំណឹងសមស្រប និងមានឱកាសបើកសវនាការ។ ត្រូវរក្សាទុកនូវសិទ្ធិស្នើសុំ ឬជំទាស់សេចក្តីសម្រេចផ្តល់កម្រៃ និង/ឬចំណាយលើអត្ថប្រយោជន៍រួម ទាក់ទងនឹងដំណោះស្រាយ សាលក្រម ឬមូលនិធិដទៃទៀតចេញពីគ្រោះថ្នាក់ Macondo / Deepwater Horizon ដែលមិនស្ថិតក្រោមលក្ខខណ្ឌដកយកនៃដីការនេះឡើយ។

ចុងចម្លើយត្រូវស្នើដាក់ប្រាក់កក់ទាំងនោះទៅក្រឡាបញ្ជីរបស់តុលាការ ដែលមានអាសយដ្ឋាន 500 Poydras Street, Room C-151, New Orleans, Louisiana 70130 សម្រាប់ការដាក់ប្រាក់កក់នៅក្នុងគណនី MDL No. 2179 និងរក្សាទុក សម្រាប់ការចំណាយក្នុងរឿងវិវាទនៃអត្ថប្រយោជន៍រួម ("MDL No. 2179 គណនីបម្រុងទុក")។ រាល់ប្រាក់កក់ទាំងអស់ដាក់ក្នុងគណនីបម្រុងទុក MDL No. 2179 នឹងត្រូវបានភ្ជាប់ដោយព័តមានដែលអាចកំណត់អំពីភាគីនិងមេធាវីដែលបង់ប្រាក់កក់។ ចុងចម្លើយដែលមានតំណាងបង់ប្រាក់

ដំណោះ ស្រាយសរុប សាលក្រម ឬមូលនិធិដទៃទៀត និងដើមចោទ អ្នកប្តឹងទាមទារសំណង ឬសមាជិកក្រុម ដែលត្រូវបង់ដំណោះស្រាយ សាលក្រម ឬមូលនិធិដទៃទៀតទៅឲ្យ។

ព័ត៌មានទាំងនោះត្រូវតែរក្សាជាការសំងាត់ ហើយការមើលព័តមានទាំងនោះត្រូវមាន កម្រិតយោងតាមនីតិវិធីដែលបានកំណត់នៅក្នុងបទបញ្ជារបស់សវនការបឋមលេខ 9។ តាមរយៈនេះ Phil Garrett CPA ត្រូវតាមដានព័ត៌មានទាំងនោះនិងធ្វើរបាយការណ៍តាមកាលកំណត់ទៅតុលាការនិងដើមចោទ Co-Liaison។ រាល់ការបង្ហាញព័ត៌មានទាំងនោះតម្រូវឲ្យមានបទបញ្ជារអនុញ្ញាតិពីតុលាការនេះ។

គ្មានភាគីឬមេធាវីណាមួយមានសិទ្ធិតម្កល់អ្វីឬរក្សាមូលនិធិ នៅក្នុងគណនីសម្រាប់ទូទាត់សំណងដែលគ្រប់គ្រងដោយតុលាការនេះទេ ហើយមូលនិធិទាំងនេះមិនអាចបង្កើតជាទ្រព្យសម្បត្តិដោយឡែករបស់ភាគី ឬមេធាវីណាមួយឡើយ ឬជាកម្មវត្ថុនៃរឹបអូសរបស់ភាគីឬមេធាវីណាមួយឡើយ។ មូលនិធិទាំងនោះមិនអាចត្រូវបានចាត់ចែង ចំណាយ ឬបែងចែកឡើយ លើកលែងតែមានបទបញ្ជាអនុញ្ញាតបន្ថែមពីតុលាការនេះ។

រាល់សំណួរនានាដែលទាក់ទងនឹងនីតិវិធីដាក់ពាក្យបណ្តឹងជាមួយនឹងក្រឡាបញ្ជីតុលាការ សូមទាក់ទងទៅលោក Kim Lange ផ្នែកហិរញ្ញវត្ថុ ក្រឡាបញ្ជីតុលាការ ទូរស័ព្ទ: 504-589-7786 kim_lange@laed.uscourts.gov ដោយផ្ទាល់។ រាល់ចម្ងល់ទាក់ទងនឹងប្រាក់កក់ សូមទាក់ទងផ្ទាល់ជាមួយ Philip Garrett, CPA, Garrett and Company CPA's, 117 Fairgrounds Boulevard, Bush, Louisiana 70431, ទូរស័ព្ទ 985-635-1500, pgarrett@garrettco.com។

**បានចុះហត្ថលេខានៅ** New Orleans, Louisiana, ថ្ងៃទី 18 ខែ មករា ឆ្នាំ 2012

ហត្ថលេខា
ចៅក្រមនៃតុលាការដំបូងរបស់សហរដ្ឋអាមេរិក